

# រឿងមេអំបៅខ្ជិលនិង
# ស្រមោចឧស្សាហ៍

Let's Read
The Asia Foundation



ថ្ងៃមួយ ស្រមោចកំពុងព្យាយាមយ៉ាង
លំបាកយកនំប៉័ងមួយដុំចូលទៅ
ក្នុងផ្ទះរន្ធឈើរបស់វា។ ពេលនោះ
មេអំបៅដែលទំនៅលើស្លឹកបានសំលឹង
មើលទៅស្រមោច "អ៊ុំ "នុះជាស្អីគេ
អញ្ចេះ ?' មេអំបៅមានការងឿងឆ្ងល់ជា
ខ្លាំងនូវអ្វីដែលស្រមោចកំពុងធ្វើ។ ទ្រាំ
និងចម្ងល់មិនបានមេអំបៅក៏ស្រែកហៅ
ស្រមោច ————————————
——– "ស្រមោច ស្រមោចហ្អា៎! តើ
ឯងកំពុងធ្វើអ្វី? តោះ លេងជាមួយខ្ញុំ!
" សួស្តី! មេអំបៅ។ ខ្ញុំក៏ចង់លេងដែរ
ប៉ុន្តែឥឡូវនេះ ខ្ញុំមិនអាចលេងបានទេ។
រដូវវស្សានឹងចាប់ផ្តើមក្នុងពេលឆាប់ៗ



នេះ, មុនរដូវវស្សាមកដល់ត្រូវប្រមូល
អាហារទុកឱ្យបានច្រើន» ស្រមោចបាន
ឆ្លើយទៅមេអំបៅទាំងដង្ហើមហត់ទ្រ
ហេស



នែ៎ ស្រមោច នៅទីនេះមានអាហារ
ច្រើនយ៉ាងនេះ ហេតុអ្វីបានជាឯង
ប្រឹងប្រែងធ្វើការម្ល៉េះ? មើលនោះន៎។
ឯងមានឃើញមិត្តរបស់ខ្ញុំឯវាលស្មៅ
នោះទេ? មេអំបៅបានចង្អុលបង្ហាញ
ប្រាប់ថាមិត្តរបស់គេនៅវាលស្មៅ។ —
——————————————- ”តើ
ម្នាក់នឹងជានរណា?” ” អឺ, កណ្តូបជា
មិត្តរបស់ខ្ញុំ ម្នាក់និងមិនព្រួយបារម្ភ
អំពីអ្វីនោះឡើយ។ កណ្តូបប្រាប់ថា
គ្រប់កន្លែងមានអាហារជាច្រើន មិន
ចាំបាច់ធ្វើការអ្វីទេ ហើយ កណ្តូប
ច្រៀងក៏ពិរោះនិងតែងតែធ្វើឱ្យខ្ញុំ
សប្បាយចិត្ត។ មានកណ្តូបក្បែរខ្លួន



រឿងមិនល្អនឹងមិនកើតឡើងដល់ខ្ញុំឡើយ ។ មេអំបៅនិយាយដោយអំនួត។ ’អ៊ូ មែនរឺ ស្រមោចនៅតែបន្តរធ្វើការ ន៎ ស្រមោច, សាកគិតមើល មិនបាច់ធ្វើអីគ្រាន់តែច្រៀង ខ្ញុំនៅតែមានអាហារទទួលទាន មិនខ្វល់អ្វីឡើយ មើលទៅឯងចុះ, យ៉ាប់ណាស់ រស់នៅឱ្យសប្បាយខ្លះទៅ’ មេអំបៅបានសើចចំអកឱ្យស្រមោច

សម្ដីរបស់មេអំបៅធ្វើអោយស្រមោចអោនក្បាលចុះ ’បើចង់ប្រមូលអាហារទុកឱ្យគ្រួសារសម្រាប់រដូវវស្សារត្រូវតែប្រឹងរកពីឥឡូវនេះទៅ។ យើងក៏ចង់លេងដូចឯងដែរ.. ’ ស្រមោចនិយាយ



ទាំងអួលដើមក។ ហើយពីមួយថ្ងៃទៅមួយថ្ងៃស្រមោចនិងគ្រួសារប្រឹងប្រែងប្រមូលអាហារជាមួយគ្នា ឈប់សម្រាក់ឡើយ។ មួយ បំណែក, ពីរ បំណែក, បី បំណែក.... នំប៉ុងបានគរឡើងនៅក្នុងផ្ទះរន្ធឈើ។ ’មួយ, ពីរ, បី, បួន.... ប្រមូលពីរផុងទៀតនឹងពេញហើយ ហត់ណាស់ លោកអើយ។

ប្រឹងបន្តិចទៀត!

បើខ្ញុំប្រឹងប្រែងបន្ថែមទៀតគ្រួសារយើងទាំងអស់នឹងអាចរស់នៅពោរពេញដោយ ក្ដីសុខ’ ស្រមោចនិយាយផ្ដល់កំលាំងចិត្តឱ្យខ្លួនឯងផងដែរ។



ពីមួយថ្ងៃទៅមួយថ្ងៃមេអំបៅមិនខ្វល់ពីអ្វីទាំងអស់គិតតែសប្បាយប៉ុន្នោះ ”ឡាឡាឡា, ឡាឡាឡា ... អរុណសួស្តី។ ណាណាណា ណាណាណា ... មេឃស្រលះ»។ មេអំបៅបានច្រៀងចំរៀងយ៉ាងសប្បាយ។ ’អាកាសធាតុពិតជាល្អណាស់ថ្ងៃនេះ! រកទៅទទួលទានអាហារពេលព្រឹកសិន!’ មេអំបៅបានជញ្ជក់យកទឹកលំអងដ៏ឆ្ងាញ់ពីផ្កា។ បន្ទាប់មក, ក៏បានជួបកណ្តូប។ ”កណ្តូប, អរុណសួស្តី! តើយើងគិតនាំគ្នាលេងអីហ្នឹងថ្ងៃនេះ?” មេអំបៅនិងកណ្តូបបានលេងពេញមួយថ្ងៃយ៉ាងសប្បាយ។



មេអំបៅនិងកណ្តូបដែលកំពុងលេង
ខ្វាត់ខ្វែងចៃដន្យបានប្រទះឃើញ
ស្រមោចដែលកំពុងលីអីវ៉ាន់ដ៏ធ្ងន់
ដើឆ្លងកាត់ ។ ”នែ៎ កណ្តូប ឯងមើល
ស្រមោចនោះ មួយថ្ងៃៗខំធ្វើការ
មិនឈប់សូម្បីមួយថ្ងៃឡើយ អាហារ
មិនចេះខ្វះផងណឹង ”។ មេអំបៅបាន
សើចចំអកសំដៅដល់ស្រមោច ប្រាប់
កណ្តូប។ ’មែនហ្នឹង! ស្រមោច ដូចឆ្កួត
អញ្ចឹងគិតតែធ្វើការ!’ កណ្តូបបានឆ្លើយ
ទាំងអស់សំណើច។



មួយអាទិត្យក្រោយមក, ភ្លៀងបានចាប់ផ្តើមធ្លាក់។ ហើយភ្លៀងនិងព្យុះបានបោកបក់ គ្រប់ទិសទីមានទាំងទឹកជំនន់ផងដែរ បើចេញទៅក្រៅនឹងអណ្តែតតាមទឹក មិនថាជាសត្វអ្វីក៏ដោយ សត្វល្អិតផ្សេងក៏មិនអាចរកអាហារទទួលទានបានឡើយ ជាសំណាងល្អ, ស្រមោចបានសម្រាកយ៉ាងសុខស្រួលជាមួយគ្រួសារនៅក្នុងផ្ទះរន្ធឈើដ៏មានសុវត្ថិភាព។ មានអាហារជាច្រើនដែល ត្រៀមទុកនៅផ្ទះនៃគ្រួសារស្រមោច ដូច្នេះមិនចាំបាច់ទៅខាងក្រៅ ពោរពេញដោយភ្លៀងខ្យល់និងទឹកជំនន់ឡើយ។ ពេលនោះ,



ខ្យល់បក់បោកធ្វើឱ្យរបើកបង្អួចផ្ទះស្រមោច។ ——————————————– រៀបនឹងបិទបង្អួចស្រមោចមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ខាងក្រៅបង្អួចមេអំបៅនិងកណ្តូបបានរត់ចុះឡើងនិងត្រូវទឹកភ្លៀង។ ’អូ, នែ៎មេអំបៅ, នែ៎កណ្តូប! ខ្យល់ខ្លាំងបែបនេះទៅណានឹង? គ្រោះថ្នាក់ណាស់, ប្រញាប់ទៅផ្ទះវិញទៅ! ” ស្រមោចបានស្រែកប្រាប់ដោយសំលេងលឺៗ ’ស្រមោចអើយ, ពួកយើងឃ្លានណាស់ដូច្នេះកំពុងរកចំណីអាហារ’ មេអំបៅ បានឆ្លើយទាំងញ័រខ្លួន កុំអី! មេអំបៅ, ទៅផ្ទះ



ឱ្យលឿន! វាមានគ្រោះថ្នាក់ណាស់
នៅពេលនេះ! ស្រមោចស្រែកម្តង
ទៀត។ ប៉ុន្តែមេអំបៅនិងកណ្តូប ត្រូវតែ
ចេញទៅដើម្បីរកចំណី។



”អូជួយផង! ជួយផង! ”

មេអំបៅនិងកណ្តូបបានដើរក្រោមភ្លៀងដើម្បីស្វែងរកអាហារហើយទីបំផុតបានធ្លាក់ចូលក្នុងទឹក ”មេអំបៅអើយ! កណ្តូបអើយ! ” ស្រមោចចង់ជួយមេអំបៅនិងកណ្តូបប៉ុន្តែមិនអាចចេញទៅក្រៅរួចឡើយ គ្រោះថ្នាក់បំផុតដោយសារតែទឹកលិចភូមិ បក្សីស្រែកឃ្លានពីរក្បាលបានចាប់កណ្តូបនិងមេអំបៅដែលកំពុងអណ្តែតទឹកស៊ីបាត់ទៅ ”អូមេអំបៅ! អូកណ្តូប! ឱមេអំបៅនិងកណ្តូបដ៏កំសត់អើយ”។ ស្រមោចវិញគ្មានអ្វីក្រៅពីការអាណិតអាសូឡើយ។



នៅពេលនោះ,ស្រមោចបានចងចាំនូវ
អ្វីដែល លោកតាបានមានប្រសាសន៍
កាលពេលនៅក្មេង។ ’ប្រសិនបើមិន
ត្រៀមខ្លួនសម្រាប់ថ្ងៃស្អែកវានឹងគ្មាន
ថ្ងៃស្អែកទេ។ដូច្នេះចូរឧស្សាហ៍ព្យាយាម
ជានិច្ច។’ ស្រមោចបានធ្មេចភ្នែកនិង
បានអធិដ្ឋានសម្រាប់មេអំបៅនិង
កណ្ដូប។




ប្រសិនបើអ្នកមិនរៀបចំសម្រាប់
ថ្ងៃស្អែកវានឹងមិនមានថ្ងៃស្អែកទេ។ ជា
ញឹកញាប់ត្រូវបានគេស្តាប់លឺពីកុមារ
ហ្វីលីពីន។ នៅក្នុងសុភាសិតហ្វីលីពីន
មួយ ដែលនិយាយថា ’(កាប៉ាង ម៉េ អ៊ី
ស៊ីនុកសុក, ម៉េ ម៉ាដូដូកូដ។)’ មានន័យ
ស្រដៀង ទៅនិងសុភាសិតកូរ៉េដែរ
”ជនដែលមិនត្រៀមខ្លួនសំរាប់រដូវក្តៅ
នោះនិងគ្មានរដូវរងាសំរាប់គេឡើយ”
ដែលមានថា ’បើមានការត្រៀមទុ ជា
ញឹកញាប់ត្រូវបានគេនិយាយទៅកាន់
កុមារថា ”បើសិនមិនត្រៀមសម្រាប់
ថ្ងៃស្អែកទេ ថ្ងៃស្អែកនិងមិនមានឡើយ”
ប្រសិនបើអ្នកប្រាប់ពួកគេនឹងមានក្មេង




កាន់តែច្រើនត្រៀមខ្លួនជាមុនសម្រាប់
ថ្ងៃស្អែក។


Philippines

[illegible]





រហូតមកទល់ពេលនេះអ្នកវិទ្យាសាស្ត្របានរុករកចំណេះដឹង,ប្រាជ្ញានិងបច្ចេកវិទ្យាទំនើបតែមិនអាចរកឃើញភពផ្សេងដែលមនុស្សរស់នៅបានដូច ភពផែនដី ឡើយ។តែមនុស្សទាំងនោះមិនបានឈប់រកភពផ្សេងដែលមានជីវិតរស់នៅដូចទៅនិងភពផែនដីនុះឡើយ។ គ្មាននណា,និងគ្មានក្បួនណាដែលអាចរាប់ផ្កាយជាច្រើននៃភពនិមួយៗឡើយ។តែភពដែលមនុស្សរស់នៅបានគឺភពផែនដីតែមួយគត់, អស្ចារ្យបំផុត

ពិតណាស់អារម្មណ៍រំជួលចិត្តនូវពេលដែលបានដឹងនិង។ពិសេស





នៅពេលបានធ្វើការជាមួយនារីប្រទេសផ្សេងៗនៅជុំវិញពិភពលោកដែលមកប្រទេសកូរ៉េគឺតែទទួលអារម្មណ៍រំជួលចិត្តបំផុត។ភពផែនដីតែមួយទោះយើងជាជនជាតិណាក្តីតែជា គ្រួសារផែនដី ។ គ្រួសារត្រូវទុកចិត្តគ្នា,ពឹងផ្អែកលើគ្នា,និងជួយគ្នាទៅវិញទៅមក។ គ្រួសារគឺអោបមុនគេ,សើចដាក់មុនគេ,និងលះបង់អោយមុនគេ។ គ្រួសារគឺរួមទុកជាមួយគ្នា,ជំនះការលំបាកជាមួយគ្នា,ត្រូវដើរទៅជាមួយគ្នា។

ខ្ញុំកោតសរសើរដល់អស់អ្នកដែលបានសរសេរស្នាដៃដ៏អស្ចារ្យតាមរយៈ



ការងារសៀវភៅកុមារ”រួមទាំងគ្នា រួម
ទាំងអស់គ្នា”។ដោយសារតែអ្នកចូលរួម
ទាំងអស់នោះសុទ្ធតែត្រូវចិញ្ចឹម បីបាច់
កូន,ត្រូវធ្វើកិច្ចការផ្ទះ,មើលថែបម្រើ
រមនុស្សចាស់ក្នុងផ្ទះ,និងធ្វើការងារ
ជាដើមទោះបីជាមានការនឿយហត់
យ៉ាងណាក្តីក៏បានបញ្ចប់កាងារបាន
ជោគជយ័។ពិតជាមិនងាយស្រួល
ឡើយសំរាប់ការសរសេរជាភាសាកូរ៉េ
សំរាប់អ្នកមិនទាន់ច្បាស់ទៅនិងភាសារ
នៅឡើយ។ យ៉ាងណាក្តីការសរសេរ
បង្កប់ឥទ្ធិពលដែលមិនអាចប្រៀបទៅ
និងការនិយាយរាប់រយដង។ ឥទ្ធិពល
បង្ហាញអោយឃើញច្បាស់នៅចិត្តគំនិត





ឥទ្ធិពលនៃសមាសសភាពក្នុងការ
ប្រាស្រ័យទាក់ទងជាមួយអ្នកដ៏ទៃ
ឥទ្ធិពលក្នុងការអប់រំកូនអោយបាន
ល្អ មានឥទ្ធិពលទាំងអស់នេះ ខ្ញុំសូម
ជំរុញឱ្យគម្រោងនេះកើតមានឡើង
រឹតតែច្រើន,ដែលផ្តល់មោទនភាពនិង
ក្តីសង្ឃឹមដល់ស្ត្រីចំណាកស្រុកជាច្រើន
និងគ្រួសាររបស់ពួកគេ។ អ្នកនិពន្ធ,ណ្វា
ក្យ៉ុងស៊ីល

서울특별시 SEOUL METROPOLITAN GOVERNMENT

The Asia Foundation Improving Lives, Expanding Opportunities

MoneyGram Foundation

,

.

Brought to you by

The Asia Foundation

Let’s Read! is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
□□□ □□□ □□□□□ □□, Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/

Contributing translators: Nasema Zeerak